ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង : ២៥/១០-ហាយបិន

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១០

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **រុន សារ៉ាយ**

## ភាគីនៃវិវាទ

១- ភាគីនិយោជក

ឈ្មោះ : ក្រុមហ៊ុន ហាយបិន អ៊ិនធើប្រាយ

អាសយដ្ឋាន : ភូមិម័ល សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៧១៦ ០៤៨ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

| | |
|---|---|
| ១- លោក Liu Xiao Fei | អ្នកគ្រប់គ្រងរោងចក្រ |
| ២- កញ្ញា ទិត្យ ចិន | ជំនួយការរដ្ឋបាល |
| ៣- កញ្ញា កៅ វ៉ាន់ | ជំនួយការរដ្ឋបាល |

២- ភាគីកម្មករនិយោជិត

ឈ្មោះ : - សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា

- សហជីពសេរីកម្មករ នៃរោងចក្រកាត់ដេរ ហាយ បិន

អាសយដ្ឋាន : ភូមិម័ល សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ



ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥.២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh ◆ Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org ◆ Website: www.arbitrationcouncil.org

លេខទូរស័ព្ទ : ០១២ ២៦៣ ៥៤៣ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោក ប៉ាវ ស៊ីណា មន្ត្រីសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា

២- លោក គង ឈុន ប្រធានសហជីពសេរីកម្មករ នៃរោងចក្រ ហាយ ប៊ិន

៣- កញ្ញា ហ៊យ រត្នមុនី លេខាធិការសេរីកម្មករ នៃរោងចក្រ ហាយ ប៊ិន

៤- កញ្ញា រិន ចាន់រដ្ឋា អគ្គហិរញ្ញិកសហជីពសេរីកម្មករ នៃរោងចក្រ ហាយ ប៊ិន

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ថ្លៃបាយចំនួន ១០០០ រៀល បន្ថែមទៀត ពេលធ្វើការបន្ថែមម៉ោង ចាប់ពីម៉ោង ៤ ដល់ម៉ោង ៦។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ចំពោះប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ចាប់ពីម៉ោង ៤ ដល់ម៉ោង ៦ ក្រុមហ៊ុនផ្តល់ឱ្យចំនួន ១០០០ រៀល តាមសេចក្តីជូនដំណឹងលេខ ០១៧ សកបយ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៩០ កប/ប្រក ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ (អាណត្តិទី៧)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ២៣១ ក.ប/អក/វ.ក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១០។

## សវនាការ និង សន្ទនីតិវិធី

ទីកន្លែងសវនាការ : ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី) សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ"។

កាលបរិច្ឆេទសវនាការ : ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១០ (វេលាម៉ោង ១៤:០០ នាទី រសៀល)។

THE ARBITRATION COUNCIL

បញ្ហានៃនីតិវិធី ៖

នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្ដឹងរបស់សហជីព សេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជាលេខ ១៣៧/០១០ សសកពក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១០ ស្ដីពីការទាមទារឱ្យក្រុមហ៊ុនកែលំអរល័ក្ខខណ្ឌការងារឱ្យបានល្អប្រសើរ ។ បន្ទាប់ពីបានទទួលពាក្យបណ្ដឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះជាបន្តបន្ទាប់ និងផ្សះផ្សាលើកចុងក្រោយនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០១០ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ១៣ ចំណុច លើការទាមទារចំនួន ១៤ ចំណុច ។ ដូចនេះ ចំណុចវិវាទដែលនៅសល់ គឺមានតែមួយចំណុចប៉ុណ្ណោះ ។ ចំណុចវិវាទដែលមិនសះជាចំនួន ០១ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១០ ។

បន្ទាប់ពីបានទទួលសំណុំរឿងនេះរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០១ ចំណុចនេះ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១០ (វេលាម៉ោង ០២:០០ នាទី រសៀល) ។ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានព្យាយាមធ្វើការផ្សះផ្សារលើចំណុចវិវាទ ០១ ចំណុចនេះបន្ថែមទៀត ប៉ុន្តែជាលទ្ធផលពុំបានសះជានឹងគ្នាទេ ។ ដូច្នេះ នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការពិចារណា ដោយផ្អែកលើភស្តុតាង និងហេតុផលដូចខាងក្រោម៖

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្ដាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- កិច្ចព្រមព្រៀងរវាងក្រុមហ៊ុន ហាយប៊ិន ជាមួយនឹងប្រតិភូតំណាងកម្មករ និង សហជីព នៃរោងចក្រ ហាយប៊ិន អ៊ិនធ័រប្រាយ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ ។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- សារណាពាក់ព័ន្ធសំណុំរឿងក្រុមហ៊ុន ហាយ ប៊ិន ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០ ។

២- បញ្ជីឈ្មោះឯកសារ (ថតចម្លង) ជូនភ្ជាប់មកជាមួយសារណា ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០ ។

៣- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ហាយប៊ិន ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ។

៤- លិខិតរបស់សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា គោរពជូន លោកប្រធាននាយកដ្ឋានវិវាទការងារ ស្ដីពីការប្ដឹងនាយកក្រុមហ៊ុនតម្បាញ ហាយ ប៊ិន ស្ដីពីការមិនអនុវត្តច្បាប់ស្ដីពីការងារ លេខ

THE ARBITRATION COUNCIL

១៣៧/០១០ សសកពក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១០។

៥- លិខិតរបស់សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា គោរពជូន លោកអគ្គនាយករោងចក្រ តម្បាញ ហាយ ប៊ិន ស្តីពីការសុំជួបពិភាក្សាជាមួយលោកអគ្គនាយករោងចក្រតម្បាញ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១០ លេខ ០២០/០១០ សសកពក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០។

៦- លិខិតស្នើសុំរបស់តំណាងកម្មករ និងថ្នាក់ដឹកនាំសហជីពសេរីកម្មករ ប្រចាំរោងចក្រ ហាយ ប៊ិន គោរពជូន លោកប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីសំណើសុំលោកប្រធាន មេត្តាជួយដោះស្រាយនូវលក្ខខណ្ឌការងារមួយចំនួន ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១០។

៧- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពសេរីកម្មករ នៃរោងចក្រកាត់ដេរ ហាយ ប៊ិន ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៦។

៨- លិខិតរបស់លោកប្រធាននាយកដ្ឋានវិវាទការងារ ជំរាបមក លោកប្រធានសហជីពសេរីកម្មករ នៃ រោងចក្រកាត់ដេរ ហាយប៊ិន លេខ ៣០០ កប/អក/វក ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំ សហជីពថ្មី អាណត្តិទី២ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៩។

៩- លក្ខន្តិកៈសហជីពសេរីកម្មករ នៃរោងចក្រកាត់ដេរ ហាយ ប៊ិន ចុះបញ្ជិកាលេខ ៩៩២ កកបវ/វក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៦។

១០- សេចក្តីជូនដំណឹងលេខ ០១៧ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០។

១១- វិញ្ញាបនប័ត្របញ្ជាក់ភាពជាតំណាងបំផុត សហជីពសេរីកម្មករ នៃរោងចក្រកាត់ដេរ ហាយប៊ិន លេខ ០៣៥/០៨ ក.ប./វប ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៨។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ហាយប៊ិន លេខ ២៣១ ក.ប/អក/វ.ក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ហាយប៊ិន ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ១៣៩ កប/អក/វក/លកអ. ចុះថ្ងៃទី០៥ ខែ មីនា ឆ្នាំ២០១០។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ១៤០ កប/អក/វក/លកអ. ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១០។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- ក្រុមហ៊ុន ហាយ ប៊ិន បានចាប់ផ្តើមដំណើរការនៅក្នុងខែធ្នូ ឆ្នាំ២០០១ ដែលបច្ចុប្បន្ននេះ មានជួលកម្មករនិយោជិត ចំនួនប្រហែល ៦៥០ នាក់ ។
- នៅក្នុងក្រុមហ៊ុននេះ មានសហជីពតែមួយទេ គឺ សហជីពសេរីកម្មករ ប្រចាំរោងចក្រកាត់ដេរ ហាយ ប៊ិន ដែលបានចុះបញ្ជិកាសហជីព នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៦ ។ សហជីពនេះមានសមាជិកចំនួន ៣៨០នាក់ ហើយគឺជាដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ ។ សហជីពនេះ បានទទួលវិញ្ញាបនប័ត្របញ្ជាក់ភាពជាតំណាងបំផុត នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៨ ។

**ចំណុចវិវាទៈ កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ថ្លៃបាយ ចំនួន ១០០០ រៀល បន្ថែមទៀត ពេលធ្វើការបន្ថែមម៉ោងចាប់ពីម៉ោង ០៤ ដល់ម៉ោង ០៦**

- ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់លុយថ្លៃបាយ ចំនួន ២០០០ រៀល នៅពេលដែលពួកគាត់ធ្វើការបន្ថែមម៉ោងចំនួន ០២ ម៉ោង គឺពីម៉ោង ០៤ ដល់ម៉ោង ០៦ ។ មូលហេតុនៃការទាមទារនេះ គឺសំអាងទៅលើទំនិញទីផ្សារឡើងថ្លៃ ហើយទឹកប្រាក់ចំនួន ១០០០ រៀល ដែលក្រុមហ៊ុនផ្តល់ឱ្យនោះ មិនអាចទិញបាយហូបបានទេ។ ម្យ៉ាងទៀត បើក្រុមហ៊ុនធ្វើការផ្តល់ជូននេះ វាគឺជាការលើកទឹកចិត្តមួយដល់កម្មករនិយោជិតឱ្យរឹតតែខិតខំធ្វើការងារ និងជួយដល់ក្រុមហ៊ុននៅពេលធ្វើការបន្ថែមម៉ោងថែមទៀត ។ កម្មករនិយោជិតបានលើកឡើងបន្ថែមទៀតថា ក្រុមហ៊ុនដទៃក៏បានផ្តល់ជូនដូចនេះដែរ ។ ភាគីនិយោជកមិនឆ្លើយតបនឹងការលើកឡើងនេះទេ ។
- ភាគីនិយោជកបានអះអាងបញ្ជាក់វិញថា ច្បាប់បានតម្រូវឱ្យនិយោជកផ្តល់ជូនកម្មករនិយោជិត តែចំនួន ១០០០ រៀលប៉ុណ្ណោះក្នុងមួយថ្ងៃ នៅពេលដែលកម្មករនិយោជិតស្ម័គ្រចិត្តធ្វើការងារបន្ថែមម៉ោង ។ ដូចនេះ និយោជកសូមអនុវត្តទៅតាមច្បាប់ ។ ទន្ទឹមនឹងនេះដែរ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ ភាគីកម្មករនិយោជិត ដែលមានប្រតិភូតំណាងកម្មករ និងសហជីព បានធ្វើកិច្ចព្រមព្រៀងមួយ ជាមួយនិយោជក ដោយនិយោជកត្រូវផ្តល់ប្រាក់ថ្លៃបាយចំនួន ១០០០ រៀល ចំពោះកម្មករនិយោជិត ដែលយល់ព្រមធ្វើការថែមម៉ោងចំនួន ២ ម៉ោង រីឯកម្មករនិយោជិតដែលយល់ព្រមធ្វើការថែមម៉ោង ចំនួន ៤ ម៉ោង

និយោជកនឹងផ្តល់ប្រាក់ថ្លៃបាយ ចំនួន ២៥០០ រៀល ។

- ភាគីកម្មករនិយោជិត និងនិយោជក បានឯកភាពគ្នាថា ជាទូទៅ នៅក្នុងក្រុមហ៊ុននេះ មានការបន្ថែមម៉ោង ចំនួនប្រហែល ២០ ដង ក្នុងមួយខែ ហើយការថែមម៉ោងម្តងៗ ពេលខ្លះមានចំនួន ២ ម៉ោង ហើយពេលខ្លះ មានចំនួន ៤ ម៉ោង ។ នៅក្នុងក្រុមហ៊ុននេះ នៅពេលដែលកម្មករនិយោជិតធ្វើការបន្ថែមម៉ោង គឺនិយោជក មិនដែលផ្តល់បាយទេ ប៉ុន្តែផ្តល់ជាប្រាក់ថ្លៃបាយចំនួន ១០០០ រៀល ហើយកន្លងមក ភាគីទាំងពីរពុំដែល បានធ្វើកិច្ចព្រមព្រៀងណាមួយ ស្តីពីការតំឡើងនៃប្រាក់ថ្លៃបាយនេះទេ ។

## ហេតុផលនៃសេចក្តីសម្រេចៈ

**ចំណុចវិវាទៈ កម្មករនិយោជិត នៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ថ្លៃបាយ ចំនួន ១០០០ រៀល បន្ថែមទៀត ពេលធ្វើការបន្ថែមម៉ោងចំនួន ពីរម៉ោង ចាប់ពីម៉ោង ០៤ ដល់ម៉ោង ០៦**

នៅក្នុងករណីនេះ ភាគីកម្មករនិយោជិតបានធ្វើការទាមទារឱ្យនិយោជកផ្តល់ប្រាក់ថ្លៃបាយចំនួន ២០០០ រៀល នៅពេលដែលពួកគាត់ធ្វើការបន្ថែមម៉ោងចំនួន ២ម៉ោង ដោយរាប់ចាប់ពីម៉ោង ០៤ ដល់ម៉ោង ០៦ ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងធ្វើការពិចារណាដូចតទៅ :

សេចក្តីជូនដំណឹងលេខ ០១៧ សកបយ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០ ចំណុចទី៤ ចែងថា *" កម្មករនិយោជិត ដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោងតាមសំណូមពររបស់និយោជក ត្រូវបានប្រាក់ថ្លៃបាយចំនួន ១០០០ រៀល ក្នុងមួយថ្ងៃ ឬទទួលបានការផ្តល់ជូនថ្លៃបាយមួយពេល ដោយឥតគិតថ្លៃ "* ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ចំណុច៤ នៃសេចក្តីជូនដំណឹងខាងលើនេះ ចែងថា បើធ្វើការបន្ថែមម៉ោងតាមសំណូមពររបស់និយោជក ត្រូវបានប្រាក់ថ្លៃបាយចំនួន ១០០០រៀល ក្នុងមួយថ្ងៃ ឬទទួលបានការផ្តល់ជូនបាយមួយពេលដោយឥតគិតថ្លៃ ប៉ុន្តែចំណុចនេះ ពុំបានបង្ហាញថា តើត្រូវធ្វើការបន្ថែមម៉ោងនេះ ចំនួនប៉ុន្មាននោះទេ ។

តាមរយៈអង្គហេតុ ភាគីកម្មករនិយោជិត និងនិយោជក បានធ្វើកិច្ចព្រមព្រៀងមួយ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ ដោយក្នុងនោះមានតំណាងប្រតិភូបុគ្គលិក តំណាងខាងសហជីពប្រចាំរោងចក្រ និងភាគីនិយោជកចូលរួម ។ កិច្ចព្រមព្រៀងនោះចែងថា និយោជកត្រូវផ្តល់ប្រាក់ថ្លៃបាយ ចំនួន ១០០០រៀល ចំពោះកម្មករនិយោជិត ដែលយល់ព្រមធ្វើការថែមម៉ោងចំនួន ០២ ម៉ោង ហើយចំពោះកម្មករនិយោជិត ដែលយល់ព្រមធ្វើការថែមម៉ោងចំនួន ០៤ ម៉ោង និយោជកនឹងផ្តល់ប្រាក់ចំនួន ២៥០០ រៀល ។ ក្នុងករណីនេះ ភាគីនិយោជកបានផ្តល់ជូនកម្មករនិយោជិតនូវទឹកប្រាក់ចំនួន ១០០០ រៀល ក្នុងមួយថ្ងៃ ចំពោះកម្មករនិយោជិត ដែលបានស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោងចំនួនពីរម៉ោង ទៅតាមកិច្ចព្រមព្រៀងរវាងភាគីនិយោជក និងកម្មករនិយោជិតរួចហើយ ។ ប៉ុន្តែ ក្នុងករណីនេះ ភាគីកម្មករនិយោជិតធ្វើការទាមទារឱ្យនិយោជកផ្តល់ប្រាក់ថ្លៃបាយចំនួន ២០០០ រៀល ដល់កម្មករ

THE ARBITRATION COUNCIL

និយោជិត ដែលធ្វើការបន្ថែមម៉ោងចំនួនពីរម៉ោង ក្នុងមួយថ្ងៃ ដែលភាគីនិយោជកមិនយល់ព្រមតាមការស្នើសុំនោះទេ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាថា តើកម្មករនិយោជិតអាចកែប្រែកិច្ចព្រមព្រៀងដែលភាគីកម្មករនិយោជិត និងភាគីនិយោជក បានធ្វើឡើងតាមរយៈការទាមទារនេះដែរឬទេ?

មាត្រា៦៥ នៃច្បាប់ស្តីពីការងារ ចែងថា "កិច្ចសន្យាការងារ គឺជាកិច្ចសន្យាដែលបង្កើតឱ្យមានការទាក់ទងផ្នែកការងាររវាងកម្មករនិយោជិត និងនិយោជក។ កិច្ចសន្យានេះ ត្រូវនៅក្រោមវិធាននៃអាជ្ញាគតិ ហើយអាចធ្វើទៅតាមទម្រង់ដែលភាគីទាំងសងខាងព្រមព្រៀងគ្នា ។"

មាត្រា ១ នៃក្រឹត្យ-ច្បាប់លេខ ៣៨ ក្រ.ច ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ចែងថា "*កិច្ចសន្យា គឺជាឆន្ទៈព្រមព្រៀងរវាងបុគ្គល ២ នាក់ ឬច្រើននាក់ ដើម្បីបង្កើត កែប្រែ ឬរំលត់កាតព្វកិច្ចមួយ ឬច្រើនដែលទាក់ទិននឹងខ្លួន ។*"

មាត្រា២២ នៃ ក្រឹត្យ-ច្បាប់ ដដែល ចែងថា " *កិច្ចសន្យា គឺជាច្បាប់របស់គូភាគី ។ កិច្ចសន្យានឹងអាចកែប្រែបាន លុះត្រាតែមានការយល់ព្រមពីគូភាគី... ។* "

តាមរយៈមាត្រា២២ នៃក្រឹត្យ-ច្បាប់ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កិច្ចសន្យា គឺទុកជាចំណងច្បាប់ ដែលត្រូវអនុវត្តចំពោះភាគីកម្មករនិយោជិត និងភាគីនិយោជក។ ( *សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ៣៩/០៩- ឃ្វីនធ៍ មេជើរ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី២*) ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងសំណុំរឿងមុនដែរ ។

យោងតាមបញ្ញត្តិនៃមាត្រាខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងសំណុំរឿងមុនៗ យល់ឃើញថា មានតែភាគីនៃកិច្ចសន្យាទេទើបមានសិទ្ធិរំលាយ ឬបញ្ចប់កិច្ចសន្យាការងារនេះបាន។ ( *សូមមើលសេចក្តីបង្គាប់របស់អាជ្ញាកណ្តាល លេខ ៥៤/០៨-ចុង យ៉ូវ ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី ៥*) ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កិច្ចព្រមព្រៀងដែលធ្វើឡើងដោយភាគីកម្មករនិយោជិត និងនិយោជកនោះ គឺជាឆន្ទៈមួយដែលបានបង្ហាញពីការយល់ព្រមទទួលយកនូវចំនួនប្រាក់ថ្លៃបាយ ១០០០ រៀល នៅពេលដែលគាត់ធ្វើការបន្ថែមម៉ោង ចំនួន ០២ ម៉ោង ក្នុងមួយថ្ងៃ ។

ដូចនេះ យោងតាមមាត្រា២២ នៃក្រឹត្យ-ច្បាប់ លេខ ៣៨ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិត ដែលសុំទាមទារឱ្យនិយោជក ផ្តល់ជូនប្រាក់ថ្លៃបាយចំនួន ១០០០ រៀលបន្ថែមទៀតនោះ លុះត្រាតែមានការយល់ព្រមពីភាគីនិយោជក។ នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីនិយោជកមិនបានយល់ស្របទៅនឹងការកែប្រែកិច្ចព្រមព្រៀង តាមរយៈការទាមទាររបស់ភាគីកម្មករនិយោជិតនោះទេ ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាល សម្រេចបដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជក ផ្តល់ប្រាក់ថ្លៃបាយ ចំនួន ១០០០ រៀល បន្ថែមទៀត ពេលធ្វើការបន្ថែមម៉ោងចាប់ពីម៉ោង ០៤ ដល់ម៉ោង ០៦ ។

យោងតាមអង្គហេតុ ដែលបានរកឃើញ អង្គច្បាប់ និងហេតុផលដូចបានពន្យល់ខាងដើម ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច ដូចតទៅនេះ:

## សម្រេច និង បង្គាប់

**ចំណុចវិវាទ:**

បដិសេធការទាមទាររបស់កម្មករនិយោជិត ដែលឱ្យនិយោជក ផ្តល់ប្រាក់ថ្លៃបាយ ចំនួន ១០០០ រៀល បន្ថែមទៀត ពេលធ្វើការបន្ថែមម៉ោងចាប់ពីម៉ោង ០៤ ដល់ម៉ោង ០៦ ។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : អ៊ុំ សុធី

ហត្ថលេខា: ------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : អេន ណេន

ហត្ថលេខា: ------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : នួន សាវ៉ាយ

ហត្ថលេខា: ------------------------------------